ក្រសួងព័ត៌មាន
មកដល់ថ្ងៃទី ១៩-០៨-១៧
ម៉ោង ៩:០០
លេខ ១២២២ ពម

# ព្រះរាជក្រម

នស/រកម/០៧១៧/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៦/០២៦/២០១៧ កបធ.ច ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការបោះឆ្នោតជ្រើសតាំង
# សមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ។

**មាត្រា ២.-**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យសប្តាហ៍ទី ៨ មុនដំណាច់ឆ្នាំទី ៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

# ជំពូកទី ២
## ចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ

**មាត្រា ៤.-**

ព្រឹទ្ធសភា មានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៥.-**

សមាជិកព្រឹទ្ធសភាចំនួន ២(ពីរ) រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

**មាត្រា ៦.-**

សមាជិកព្រឹទ្ធសភាចំនួន ២(ពីរ) រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៧.-**

សមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

**មាត្រា ៨.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានកំណត់ក្នុងមាត្រា ១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៩.-**

មណ្ឌលបោះឆ្នោត ត្រូវរៀបចំ និងបែងចែកជា ៨(ប្រាំបី) ភូមិភាគ ។

អាសនៈនៅក្នុងព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំង ត្រូវកំណត់ត្រឹមចំនួន ៥៨ (ហាសិបប្រាំបី ) ដោយបែងចែកតាមភូមិភាគ ដូចខាងក្រោម ៖

-ភូមិភាគទី ១ រាជធានីភ្នំពេញ មាន ៦ (ប្រាំមួយ) អាសនៈ

-ភូមិភាគទី ២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ មាន ៨ (ប្រាំបី) អាសនៈ

-ភូមិភាគទី ៣ ខេត្តកណ្តាល មាន ៥ (ប្រាំ) អាសនៈ

-ភូមិភាគទី ៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន មាន ១០ (ដប់) អាសនៈ

-ភូមិភាគទី ៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប មាន ៧ (ប្រាំពីរ) អាសនៈ

-ភូមិភាគទី ៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង មាន ៧ (ប្រាំពីរ) អាសនៈ

-ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ មាន ៩ (ប្រាំបួន) អាសនៈ

-ភូមិភាគទី ៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី មាន ៦ (ប្រាំមួយ) អាសនៈ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៣
## អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីបោះឆ្នោត
## និងការិយាល័យបោះឆ្នោត

**មាត្រា ១០.-**

អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។

**មាត្រា ១១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីនេះយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

បញ្ជីបោះឆ្នោត ដែលត្រូវបានផ្តល់សុពលភាពហើយ មិនអាចកែប្រែបានទេ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

ក្នុងករណី មានសមាជិកណាម្នាក់នៃអង្គបោះឆ្នោត ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ស្ថាប័នមានសមត្ថកិច្ច ត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកអង្គបោះឆ្នោតនោះ ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បិទផ្សាយបញ្ជីបោះឆ្នោតដំបូងយ៉ាងតិច ៤៨ (សែសិបប្រាំបី) ថ្ងៃ មុនថ្ងៃបោះឆ្នោត នៅទីប្រជុំជនរាជធានី ខេត្ត ។

ដើម្បីបោះឆ្នោតបាន អ្នកមានសិទ្ធិបោះឆ្នោត ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- -មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- -មានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- -មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- -ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ១២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោតនៅទីប្រជុំជនរាជធានី ខេត្ត នីមួយៗ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៤

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
## និងបញ្ជីបេក្ខជនឈរឈ្មោះ

**មាត្រា ១៣.–**

មាត្រា២៣ ២៤ ២៥ ២៦ ២៧ ២៨ ២៩ ៣០ ៣១ ៣២ ៣៣ ៣៤ ៣៥ ៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប៉ុន្តែបេក្ខជននេះ ត្រូវមានអាយុយ៉ាងតិច ៤០ (សែសិប) ឆ្នាំ ។

**មាត្រា ១៤.–**

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនពេញសិទ្ធិស្មើនឹងចំនួនអាសនៈនៃភូមិភាគនីមួយៗ និងបេក្ខជនបម្រុងមានចំនួនស្មើនឹងបេក្ខជនពេញសិទ្ធិរៀបតាមលំដាប់លេខរៀង ដូចជាការរៀបចំបញ្ជីបេក្ខជនតំណាងរាស្ត្រដែរ ។

**មាត្រា ១៥.–**

បទបញ្ញា និងនីតិវិធីទាំងឡាយ ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

# ជំពូកទី ៥

## ការឃោសនាបោះឆ្នោត

**មាត្រា ១៦.–**

ការឃោសនាបោះឆ្នោត មានទិសដៅឲ្យបេក្ខជន និងគណបក្សនយោបាយ ដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ។

**មាត្រា ១៧.–**

ការឃោសនាបោះឆ្នោត ត្រូវធ្វើនៅតាមមណ្ឌលភូមិភាគនីមួយៗ ។

យុទ្ធនាការឃោសនាបោះឆ្នោត មានរយៈពេល ១៤ ( ដប់បួន ) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ ( ម្ភៃបួន ) ម៉ោងមុនថ្ងៃបោះឆ្នោត ។

**មាត្រា ១៨.-**

មាត្រា៦៨ ៦៩ ៧០ ៧១ កថាខ័ណ្ឌទី២ នៃមាត្រា៧២ មាត្រា៧៣ ៧៤ ៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ និងមាត្រា៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ដោយឡែក ចំពោះការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅក្នុងមណ្ឌលភូមិភាគនីមួយៗ ត្រូវកំណត់យ៉ាងច្រើន ២ (ពីរ)ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

## ជំពូកទី ៦

## ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត

**មាត្រា ១៩.-**

គណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ២(ពីរ) រូប ពេញសិទ្ធិ ១(មួយ) រូប និងបម្រុង ១(មួយ) រូប ដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

សិទ្ធិ តួនាទី និងលក្ខខណ្ឌផ្សេងៗ ក្នុងការស្នើសុំជាភ្នាក់ងារគណបក្សនយោបាយ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២០.-**

មាត្រា១០ ១១ ១២ ១៣ ១៤ ១៥ ១៦ ១៧ ១៨ ១៩ ២០ ២១ និងមាត្រា២២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៧

## ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត
## និងការប្រមូលសរុបលទ្ធផលនៃការបោះឆ្នោត

**មាត្រា ២១.-**

ការបោះឆ្នោតត្រូវធ្វើតែ ១(មួយ) ថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០ ( ប្រាំពីរ )ព្រឹក រហូតដល់ម៉ោង ១៥:០០( ដប់ប្រាំ ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះគ្រប់គ្នាហើយ គណៈកម្មការិយាល័យបោះឆ្នោត អាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោង ១៥ :០០ ( ដប់ប្រាំ ) ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបិទការបោះឆ្នោតនៅម៉ោង ១៥ :០០ ( ដប់ប្រាំ ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឲ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោង១៥ :០០( ដប់ប្រាំ ) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយ ម៉ោង ១៥ :០០( ដប់ប្រាំ ) ហើយអាចអនុញ្ញាតឲ្យបោះឆ្នោត គឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥ :០០ (ដប់ប្រាំ ) ។

### មាត្រា ២២.–

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅនឹងកន្លែង ក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត ។

### មាត្រា ២៣.–

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងរាជធានី ខេត្តរបស់ខ្លួន ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ ។

### មាត្រា ២៤.–

មាត្រាទាំងឡាយ ដែលមានចែងក្នុងជំពូកទី៨ អំពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត លើកលែងតែមាត្រា៩២ ១០៣ ១១៦ ១២៣ ១២៦ និងមាត្រា ១២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ញា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៨

## សមត្ថកិច្ចដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត

### មាត្រា ២៥.–

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ជាអ្នកសម្រេចដំបូងបង្អស់លើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា លើកលែងករណីវិវាទកម្មទាំងឡាយ ដែលជាសមត្ថកិច្ចដំបូងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្នុងករណីមានបណ្តឹងជំទាស់ ឬតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចពិនិត្យ និងសម្រេច ។

### មាត្រា ២៦.–

ក្នុងករណីមានបណ្តឹងជំទាស់ ឬតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចសម្រេចចុងក្រោយបិទផ្លូវតវ៉ា លើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២៧.-**

នីតិវិធីដោះស្រាយការវិវាទ ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្តឹងជំទាស់ ឬតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

## ជំពូកទី ៩

## ការបាត់បង់អាសនៈនៃព្រឹទ្ធសភា និងការជ្រើសតាំងសមាជិកជំនួស

**មាត្រា ២៨.-**

មាត្រា១៣៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការបាត់បង់អាសនៈនៃព្រឹទ្ធសភា ។

**មាត្រា ២៩.-**

សមាជិកព្រឹទ្ធសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ទៅតាមករណីណាមួយដូចខាងក្រោម ៖

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរ ពីសមាជិកព្រឹទ្ធសភា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកព្រឹទ្ធសភាណាមួយ ត្រូវបាត់បង់សមាជិកភាពមានរយៈពេល ០៦(ប្រាំមួយ) ខែ យ៉ាងតិចមុនចប់នីតិកាល ស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភា ឬសាមីគណបក្សនយោបាយនោះ អាចស្នើចាត់តាំង ឬជ្រើសតាំងសមាជិកថ្មី ឬជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះ បោះឆ្នោត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះ មកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ ។

# ជំពូកទី១០

## ទោសប្បញ្ញត្តិ

**មាត្រា ៣០.-**

ជំពូកស្តីពីទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

# ជំពូកទី១១

## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ៣២.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៧១៧.០២៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៥៨១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**